# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលព្រៃឈើ
នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

ភ្នំពេញ ថ្ងៃទី ខែឧសភា ឆ្នាំ២០១៤

ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV)

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**តាមរយៈ:** ប្រធាននាយកដ្ឋានព្រៃឈើ និង សហគមន៍ព្រៃឈើ

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV) លើកទី១០។

**ជូនភ្ជាប់:** -បញ្ជីវត្តមាន..........................................................................................ចំនួន១ច្បាប់

-ឯកសារបទបង្ហាញ...............................................................................................ចំនួន២ច្បាប់

ន័យដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ យើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេស វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់(MRV /REL) បានរៀបចំកិច្ចប្រជុំលើកទី១០ នៅសាលប្រជុំរដ្ឋបាលព្រៃឈើជាន់ទី៣ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

## I-សមាសភាពចូលរួម

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ០៨ នាក់ (ដូចបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់) មកពី៖

-រដ្ឋាភិបាលៈ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ក្រសួងបរិស្ថាន

-ក្រុមប្រឹក្សាយោបល់ៈ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) សមាគមន៍ជនជាតិដើមភាគតិចកម្ពុជា(CIYA)។

## II-គោលបំណងនៃអង្គប្រជុំ

គោលបំណងនៃអង្គប្រជុំធ្វើការពិភាក្សាស្តីអំពី៖

-ពិនិត្យស្ថាប័នពាក់ព័ន្ធចូលរួមក្នុងការអនុវត្តការងារសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងបញ្ជីសំណួរ

-បង្ហាញការសិក្សាជាសង្ខេបអំពីកត្តាដែលបណ្តាលអោយបាត់បង់ព្រៃឈើនៅកម្ពុជា

## III-ដំណើរការកិច្ចប្រជុំ

លោក **អ៊ុយ គូម៉ាល់** បានធ្វើបទបង្ហាញចែករំលែកអំពី ពិនិត្យស្ថាប័នពាក់ព័ន្ធចូលរួមក្នុងការអនុវត្តការងារសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ដោយក្នុងនោះមាន ៣ សេណារីយ៉ូ គឺ៖

**-សេណារីយ៉ូទី១:** នាយកដ្ឋានបម្រែបម្រួលអាកាសធាតុ(CCD) ទទួលខុសត្រូវក្នុងការអនុវត្តការងារសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់

**-សេណារីយ៉ូទី២:** ផ្តល់សិទ្ធិអំណាចដល់ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តការងារ

**-សេណារីយ៉ូទី៣:** ផ្តល់លិទ្ធភាពដល់ភាគីខាងក្រៅជួយអនុវត្តការងារ (Contracted Firm)

បន្ទាប់មកទៀត អង្គប្រជុំបានធ្វើការពិភាក្សាលើបញ្ជីសំណួរសម្រាប់វាយតម្លៃកម្រិតនៃការយល់ដឹងរបស់ស្ថាប័ន

ពាក់ព័ន្ធ ដែលត្រូវចូលរួមក្នុងការអនុវត្តការងារសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ដែលក្នុងនោះមានសំណួរសម្រាប់ឆ្លើយតបនឹងព័ត៌មានដូចខាងក្រោម៖

- កម្រិតនៃការយល់ដឹងរបស់ស្ថាប័ន
- កម្រិតនៃការយល់ដឹងអំពីដំណើរការរ៉េដបូករបស់ក្របខ័ណ្ឌសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ (UNFCCC) និងតម្រូវការរបស់ IPCC សម្រាប់តាមដាន LULUCF
- សមត្ថភាពរបស់មន្ត្រីបច្ចេកទេស
- តួនាទីរបស់ស្ថាប័នក្នុងដំណើរការរ៉េដបូក
- បណ្តាញការងាររបស់ស្ថាប័ននីមួយៗ
- និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត

បន្ទាប់មកទៀត លោក **ឈុន ឌីលុច** បានធ្វើបទបង្ហាញចែករំលែក ការសិក្សាជាសង្ខេបអំពីកត្តាដែលបណ្តាលអោយបាត់បង់ព្រៃឈើនៅកម្ពុជា។ វិធិសាស្ត្រដែលប្រើប្រាស់ក្នុងការសិក្សានេះគឺ៖ សិក្សាមើលឡើងវិញលើគម្រោងរ៉េដបូកអនុវត្តនៅកម្ពុជាចំនួន ២០ ដើម្បីស្វែងរកមូលហេតុ ដែលបណ្តាលអោយបាត់បង់ព្រៃឈើ និងដំណោះស្រាយព្រមទាំងធ្វើការសំភាសន៍ជំនាញការ និងមន្ត្រីរាជការ។

## IV-**លទ្ធផលនៃកច្ចប្រជុំ**

### ១.ពិនិត្យស្ថាប័នពាក់ព័ន្ធចូលរួមក្នុងការអនុវត្តការងារសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ និងបញ្ជីសំណួរ

អង្គប្រជុំសម្រេចជ្រើសរើសយកសេណារីយ៉ូទី២ និងទី៣ ដោយជំរុញអោយស្ថាប័នពាក់ព័ន្ធចូលរួមអនុវត្តការងារសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ ហើយនាយកដ្ឋានបម្រែបម្រួលអាកាសធាតុ(CCD) ជាអ្នកសម្របសម្រួល។ ចំពោះបញ្ជីសំណួរស្នើសុំបកប្រែជាភាសាខ្មែរ និងទុករយៈពេល ៣ថ្ងៃ អោយសមាជិកតំណាងស្ថាប័នផ្សេងៗពិនិត្យអោយបានល្អិតល្អន់ និងលើកជាសំណួរពាក់ព័ន្ធនឹងស្ថាប័នរបស់ខ្លួន។ ចំពោះចំណុចនេះ គិតមកដល់បច្ចុប្បន្នសមាជិកដែលជាតំណាងបានផ្តល់សំណួរពាក់ព័ន្ធមកដល់ក្រុមការងាររួចហើយ។

### ២.ការសិក្សាជាសង្ខេបអំពីកត្តាដែលបណ្តាលអោយបាត់បង់ព្រៃឈើនៅកម្ពុជា

អង្គប្រជុំបានស្នើសុំអោយសិក្សាបន្ថែម ព្រមទាំងកំណត់សុចនាករអោយបានច្បាស់លាស់ និងគួរធ្វើការកែសម្រួលចំណងជើងនៃការសិក្សាឡើងវិញ។

## VI-**ទិសដៅអនុវត្តបន្ត**

ក្រុមការងារនឹងរៀបចំកិច្ចប្រជុំលើកទី១១ នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ក្នុងគោលបំណងធ្វើការពិភាក្សាលើភាពខុសគ្នារវាង IPCC ឆ្នាំ២០០៦ និង IPCC ឆ្នាំ១៩៩៦ ព្រមទាំងពិភាក្សាគ្នាថាតើមានព័ត៌មាន និងទិន្នន័យអ្វីខ្លះអាចប្រើប្រាស់បាននាពេលបច្ចុប្បន្ន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាពិនិត្យសម្រេចដោយអនុគ្រោះតាមការគួរ ។

លេខ......................នពស

បានឃើញ និង បញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

"សូមមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះ "

ភ្នំពេញ ថ្ងៃទី ខែឧសភា ឆ្នាំ២០១៤

**ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ**